**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ )

ភាគីដាក់ឯកសារ: ក្រុមការពារក្តីរបស់អ្នកស្រី អ៊ឹម ចែម

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៨

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 14-Jun-2018, 11:20
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ : **សាធារណៈ/Public**

ប្រភេទចំណាត់ថ្នាក់ឯកសារ:

ពិនិត្យឡើងវិញចំពោះចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើអ្នកស្រី អ៊ឹម ចែម ស្នើសុំធ្វើចំណាត់ប្រភេទឯកសារមួយចំនួន**

**ដែលបានជ្រើសរើសចេញពីក្នុងសំណុំរឿង ០០៤/១**

---

**<u>ដាក់ដោយ៖</u>**

**<u>សហមេធាវី</u>**

ប៊ិត ស៊ាងលីម

Wayne JORDASH, QC

**<u>ផ្ញើជូន៖</u>**

**ចៅក្រមអង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម Oivier BEAUVALLET

ចៅក្រម ន័យ ថុល

ចៅក្រម Kang Jin BAIK

ចៅក្រម ហួត វុទ្ធី

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**ទាំងអស់ក្នុងសំណុំរឿង ០០៤/១**

## I. សេចក្តីផ្តើម

១. អ្នកស្រី អ៊ឹម ចែម តាមរយៈសហមេធាវីរបស់អ្នកស្រី ("ក្រុមការពារក្តី") ដោយអនុលោមតាម មាត្រា ៩.១ នៃសេចក្តីណែនាំការអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទឯកសារ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង និងអនុលោមតាមមាត្រា ៣.១២ និង មាត្រា ៣.១៤ នៃសេចក្តីណែនាំការអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក សូមដាក់ជូនសំណើនេះ ដើម្បីសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ ("សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ") ។

២. ក្រុមការពារក្តីសូមស្នើទៅអង្គបុរេជំនុំជម្រះដោយគោរពមេត្តាដាក់ចំណាត់ប្រភេទឯកសារឡើងវិញនូវឯកសារនានាដែលមានរាយឈ្មោះនៅក្នុងឧបសម្ព័ន្ធ A និងឧបសម្ព័ន្ធ B ដាក់ភ្ជាប់ជាមួយនឹងសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ ("ឯកសារត្រូវស្នើសុំ") ជាឯកសារសាធារណៈ ឬជាទម្រង់កោសលុបសាធារណៈ តាមការយល់ឃើញថាសមស្រប[1] ។ ការផ្តល់តាមសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនឹងធានាថា សាធារណជនអាចរកមើលបាននូវប្រវត្តិនីតិវិធី និងបញ្ហាអង្គច្បាប់នានានៃសំណុំរឿង ០០៤/១ នៅក្នុងកម្រិតទូលំទូលាយមួយ ដើម្បីជាការលើកកម្ពស់នូវតម្លាភាពក្នុងកិច្ចការរដ្ឋបាលតុលាការ និងសុចរិតភាពកេរដំណែលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") ។

៣. ការដាក់នូវសំណើមួយនេះ គឺមានភាពសមរម្យ និងទាន់ពេលវេលានៅក្នុងដំណាក់កាលនីតិវិធីបច្ចុប្បន្ន។ ប្រសិនបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)[2] ត្រូវបានបដិសេធ ហើយនីតិវិធីទាំងអស់ក្នុងសំណុំរឿង ០០៤/១ ត្រូវបានបញ្ឈប់ជាស្ថាពរ ដល់ពេលនោះអ្នកស្រី អ៊ឹម ចែម នឹងមិនអាចប្រើប្រាស់សិទ្ធិពិភាក្សាដេញដោលរបស់ខ្លួន

---

[1] សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ, ឧបសម្ព័ន្ធ A – ឯកសារដាក់ដោយក្រុមការពារក្តីអ្នកស្រី អ៊ឹម ចែម ដើម្បីធ្វើចំណាត់ប្រភេទឯកសារឡើងវិញ ("ឧបសម្ព័ន្ធ A"); សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ, ឧបសម្ព័ន្ធ B – ឯកសារដាក់ដោយអង្គចៅក្រម ដើម្បីធ្វើចំណាត់ប្រភេទឯកសារឡើងវិញ ("ឧបសម្ព័ន្ធ B") ។

[2] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ធ្វើនៅថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១៧, ឯកសារ **D308/3/1/1** ។

លើបញ្ហានេះទៀតបានទេ ។ គួរកត់សម្គាល់ថា អង្គបុរេជំនុំជម្រះយល់ឃើញថាដំណាក់កាលបច្ចុប្បន្ននេះ គឺសមស្របក្នុងការធ្វើនូវចំណាត់ឯកសារមួយចំនួនធំ ជាប្រភេទឯកសារសាធារណៈ ចំពោះឯកសារនៃសំណុំរឿង ០០៤/១ ទាំងឡាយណាដែលមានក្នុងដំណាក់កាលមុនការជំនុំជម្រះក្តី[3] ។ លើសពីនេះទៅទៀត សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ មិនមានជាប់ពាក់ព័ន្ធនឹងឯកសារទាំងឡាយណា ដែលបច្ចុប្បន្នជាប្រធានបទនៃការប្តឹងផ្តល់នៅចំពោះមុខអង្គបុរេជំនុំជម្រះឡើយ ។

## II. សាវតា

៤. នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ដើម្បីឱ្យបើកការស៊ើបអង្កេតមួយប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម[4] ។

៥. នៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon បានចោទប្រកាន់អ្នកស្រី អ៊ឹម ចែម ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ដោយចោទថា ឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តឡើងប្រហែលនៅចន្លោះពីខែ មេសា ឆ្នាំ ១៩៧៧ រហូតដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ក្នុងទីតាំងឧក្រិដ្ឋកម្មចំនួនពីរកន្លែង គឺនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង ដែលអ្នកស្រីមានឋានៈជាលេខាស្រុកព្រះនេត្រព្រះ[5] ។

៦. នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតបានបិទកិច្ចស៊ើបអង្កេតប្រឆាំងនឹង

---

[3] សេចក្តីសម្រេចលើសំណើរបស់ អ៊ឹម ចែម សុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតបរបស់គាត់ ទៅនឹងដីកាសន្និដ្ឋានស្ពាតរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨, ឯកសារ **D304/6/4** ត្រង់កថាខណ្ឌ ១៦,២៧, ៣០ និង ៣២ ។

[4] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩, ឯកសារ **D1** ។

[5] ដីកាសម្រេចដាក់អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥, ឯកសារ **D239** ។ ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំងអ៊ឹម ចែម ឯកសារ **D239.1** នៅកថាខណ្ឌ ២-៩ ។

អ្នកស្រី អ៊ឹម ចែម[6] និងបានជូនដំណឹងដល់ភាគីទាំងអស់អំពីគោលបំណងរបស់ពួកគាត់ក្នុងការលើកលែងការចោទប្រកាន់ប្រឆាំងនឹងអ្នកស្រី ហើយបានបំបែកអ្នកស្រីចេញពីកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០៤[7] ។ នៅថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេតបានបំបែកអ្នកស្រី អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤[8] ។

៧. នៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីសម្រេចច្រានចោលនូវរាល់បទចោទប្រកាន់ទាំងអស់ប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម[9] ខណៈដែលដីកាសម្រេចពេលលេញត្រូវបានដាក់ចេញនៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០១៧[10] ។ ដីកាសម្រេចនេះ បច្ចុប្បន្នជាប្រធានបទនៃបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅចំពោះមុខអង្គបុរេជំនុំជម្រះ[11] ។

៨. នៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៨ ក្រុមការពារក្តីបានដាក់សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតបរបស់ខ្លួន ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ[12] ។ នៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៨ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចម្លើយតបមួយទៅនឹងសំណើនេះ[13] ដែលក្រុមការពារក្តីបានធ្វើការឆ្លើយតបនៅថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៨[14] ។

---

6 សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **D285** ។

7 សេចក្តីជូនដំណឹងអំពីគោលបំណងលើកលែងការចោទប្រកាន់ប្រឆាំង អ៊ឹម ចែម និងបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **D286** ។

8 ដីកាសម្រេចបំបែកសំណុំរឿងទាក់ទងនឹង អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤ ចុះថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៦, ឯកសារ **D286/7** ។

9 ដីកាដំណោះស្រាយ (ផ្នែកសេចក្តីសម្រេច) ចុះនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧, ឯកសារ **D308** ។

10 ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ៣១២ ដល់ ៣១៣ និង កថាខណ្ឌ ៣២៥ ។

11 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ធ្វើនៅថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៧, ឯកសារ **D308/3/1/1** ។

12 សំណើអ្នកស្រី អ៊ឹម ចែម ស្នើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតបរបស់អ្នកស្រី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ធ្វើនៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៨, ឯកសារ **D304/6/1** ។

13 ចម្លើយតបរបស់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញរបស់ អ៊ឹម ចែម ធ្វើនៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៨, ឯកសារ **D304/6/2** ។

កាលពីថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨ អង្គបុរេជំនុំជម្រះបានចេញសេចក្តីបង្គាប់ស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតបរបស់ក្រុមការពារក្តីទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ[15] ព្រមទាំងឯកសារមួយចំនួនផ្សេងទៀតដែលមានក្នុងសំណុំរឿង ០០៤/១[16] ។

## III. ច្បាប់ជាធរមាន

៩. ក្រុមការពារក្តីសូមដាក់បញ្ចូលគ្នាដោយយោងតាមប្រវត្តិនីតិវិធី ដែលមាននៅក្នុងកថាខណ្ឌ ៧ ដល់កថាខណ្ឌ ១១ នៃសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ នូវចម្លើយតបរបស់ក្រុមការពារក្តីទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ[17] ។

## IV. ទឡ្ហីករណ៍

១០. នៅក្នុងកថាខណ្ឌមួយចំនួនខាងក្រោមនេះ ក្រុមការពារក្តីបង្ហាញឱ្យឃើញថា ការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនូវឯកសារត្រូវស្នើសុំ i) គឺដើម្បីផលប្រយោជន៍យុត្តិធម៌ និងជាការបំពេញតាម

---

[14] ការឆ្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ស្នើសុំទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ លើសំណើសុំធ្វើចំណាត់ឯកសារឡើងវិញនៃចម្លើយតបរបស់អ្នកស្រី ទៅនឹងដីកាសន្និដ្ឋានស្ថាពរ, ធ្វើនៅថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៨, ឯកសារ **D304/6/3** ។

[15] សេចក្តីសម្រេចលើសំណើរបស់ អ៊ឹម ចែម សុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតបរបស់គាត់ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨, ឯកសារ **D304/6/4** ត្រង់កថាខណ្ឌ ១៦ ។

[16] សេចក្តីសម្រេចលើសំណើរបស់ អ៊ឹម ចែម សុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតបរបស់គាត់ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨, ឯកសារ **D304/6/4** ត្រង់កថាខណ្ឌ ២៧, ៣០ និង ៣២ ។ *សូមមើលផងដែរ*, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើការកោសលុប ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨, ឯកសារ **D309/2/1/7** ត្រង់ទំព័រ ១២-១៣ ។

[17] សំណើអ្នកស្រី អ៊ឹម ចែម ស្នើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតបរបស់អ្នកស្រី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ធ្វើនៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៨, ឯកសារ **D304/6/1** ត្រង់កថាខណ្ឌ ៧ ដល់ ១១ ។

គោលដៅនៃការអប់រំ ព្រមទាំងកេរដំណែលរបស់តុលាការ និង ii) នឹងក៏មិនប៉ះពាល់ដល់សម្ភារៈតឹកតាងសម្ងាត់របស់ អ.វ.ត.ក ឡើយ ។

**ក. ការធ្វើចំណាត់ប្រភេទឯកសារឡើងវិញចំពោះឯកសារត្រូវស្នើសុំ គឺដើម្បីផលប្រយោជន៍យុត្តិធម៌ និងជាការបំពេញឱ្យគោលដៅអប់រំ និងកេរដំណែលតុលាការ**

១១. ការធ្វើចំណាត់ប្រភេទឯកសារ គឺជាការធ្វើឱ្យមានតុល្យភាពរវាងតម្រូវការជាចាំបាច់នៃការរក្សាការសម្ងាត់ និងតម្រូវការនៃតម្លាភាព[18] ។ ខណៈដែលគោលការណ៍នៃកិច្ចស៊ើបសួរតាមផ្លូវតុលាការគ្របដណ្តប់ទៅដោយភាពសម្ងាត់[19] គោលការណ៍នេះ ត្រូវតែមានតុល្យភាពជាមួយនឹងផលប្រយោជន៍យុត្តិធម៌[20] ព្រមទាំងគោលដៅនៃការអប់រំ និងកេរដំណែល[21] ។ អង្គបុរេជំនុំជម្រះបានទទួលស្គាល់ថា នៅពេលពិចារណាទៅលើការធ្វើចំណាត់ប្រភេទនៃឯកសារនានា វាជារឿងសមស្របក្នុងការគិតទៅដល់ផលប្រយោជន៍របស់ជនត្រូវចោទ និងជនរងគ្រោះ បូករួមទាំង

---

18 *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច" សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អជតក,* សេចក្តីសម្រេចលើគោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២, ឯកសារ **F30/2**, ត្រង់កថាខណ្ឌ ៥ ។

19 វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (វិសោធនកម្មលើកទី៩) ដែលបានអនុម័តឱ្យប្រើប្រាស់នៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ (វិសោធនកម្មនៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥), វិធាន ៥៦(១) ។

20 សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក (វិសោធនកម្មលើកទី៨), អវតក/០១/២០០៧/វិ.លើកទី ៨, ធ្វើនៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១២ ត្រង់មាត្រា ៣.១៤ ។

21 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើការកោសលុប ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨, ឯកសារ **D309/2/1/7** ត្រង់កថាខណ្ឌ ២៧ ។ *សូមមើលផងដែរ, រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច" សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អជតក,* សេចក្តីសម្រេចលើគោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២, ឯកសារ **F30/2**, ត្រង់កថាខណ្ឌ ៥ ។ ទាក់ទងនឹងការទទួលបានព័ត៌មានអប់រំស្តីពីដំណើរការនីតិវិធី *សូមមើលផងដែរ,* សេចក្តីណែនាំឱ្យអនុវត្តស្តីអំពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង (វិសោធនកម្មលើកទី២), អវតក/០០៤/២០០៨/វិ.លើកទី ២, ធ្វើនៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៤ ត្រង់មាត្រា ១.២ ។

តម្លាភាពនៃកិច្ចដំណើរការនីតិវិធី ព្រមទាំងផលប្រយោជន៍យុត្តិធម៌[22] ។

១២. តម្លាភាព គឺចាំបាច់ណាស់ក្នុងករណីនេះ ពីព្រោះវានឹងអាចឱ្យអ្នកជំនាញផ្នែកច្បាប់កម្ពុជា និងសាធារណជនមានការយល់ដឹងកាន់តែច្បាស់ អំពីព័ត៌មានត្រឹមត្រូវនៃនីតិវិធីតុលាការទាំងស្រុងប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម ដើម្បីឱ្យពួកគេអាចពិនិត្យពិច័យបានទាំងលើសំណើផ្សេងៗពីសំណាក់ភាគីនានា ទាំងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត និងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនៅក្នុងបរិបទពេញលេញតាមដែលអាចធ្វើទៅបាន ដែលការធ្វើដូច្នេះ គឺដើម្បីទប់ស្កាត់នូវព័ត៌មានមិនពិត និងមិនត្រឹមត្រូវជុំវិញដំណើរប្រព្រឹត្តទៅនៃសំណុំរឿង ០០៤/១ ។ លើសពីនេះទៀត តាមការមើលឃើញទាក់ទងនឹងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ គោលដៅរបស់ អ.វ.ត.ក ស្តីពីការអប់រំ និងកេរដំណែលត្រូវបានគ្របដណ្តប់ជាទូទៅលើបញ្ហាអង្គច្បាប់ និងនីតិវិធីទាំងអស់ពាក់ព័ន្ធនឹងការប្រព្រឹត្តទៅនៃសំណុំរឿង០០៤/១ ។ ជាការពិតណាស់ បើតម្លៃពិតប្រាកដនៃ អ.វ.ត.ក គឺជាតុលាការគំរូមួយសម្រាប់ប្រព័ន្ធច្បាប់របស់កម្ពុជា នោះព័ត៌មានលម្អិត និងដំណើរប្រព្រឹត្តទៅនៃរឿងរ៉ាវបែបនេះ គួរតែត្រូវផ្សព្វផ្សាយឱ្យសាធារណជនបានដឹងជាសាធារណៈ នៅក្នុងបរិបទដ៏ពេញលេញមួយតាមដែលអាចធ្វើទៅបាន ។

១៣. ហេតុដូច្នេះ ការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនឹងមិនត្រឹមតែជួយសម្រួលដល់ការបង្កើតកំណត់ត្រាសាធារណៈដ៏ត្រឹមត្រូវនៃសំណុំរឿង ០០៤/១ ក៏ដូចជាផ្តល់នូវដំណោះស្រាយលើបញ្ហាកម្រិតព័ត៌មានសម្រាប់មូលដ្ឋានសាធារណៈ ដូចពេលបច្ចុប្បន្នប៉ុណ្ណោះទេ[23] ប៉ុន្តែវាក៏នឹងជះឥទ្ធិពលវិជ្ជមានដល់វិស័យយុត្តិធម៌របស់កម្ពុជា ការលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ហើយកាន់តែទូលំទូលាយជាងនេះទៅទៀត គឺការធ្វើឱ្យកាន់តែប្រសើរឡើងនៃនីតិរដ្ឋ ។

១៤. ការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនូវឯកសារដែលត្រូវស្នើសុំ នឹងផ្តល់ឱ្យអ្នកមានវិជ្ជាជីវៈផ្នែក

---

[22] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើការកោសលុប ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨, ឯកសារ **D309/2/1/7** ត្រង់កថាខណ្ឌ ២៨ ។

[23] ការស្វែងរកឯកសារ ដែលបានដាក់នៅក្នុងសំណុំរឿង ០០៤/១ ជាប្រភេទឯកសារ "សាធារណៈ" (អង់គ្លេស) តាមរយៈការចូលមើលក្នុងប្រព័ន្ធ Zylab គឺបង្ហាញលទ្ធផលត្រឹមតែចំនួន ៥៤ ឯកសារប៉ុណ្ណោះ ។

ច្បាប់នានា និងសាធារណជនទាំងឡាយនូវបរិបទសំខាន់ៗទាក់ទងទៅនឹងបញ្ហាមួយចំនួន រួមមានដូចជា៖ កិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការពារក្ដីដើម្បីទទួលបានការអនុញ្ញាតឱ្យចូលពិនិត្យមើលឯកសារនៅក្នុងសំណុំរឿង[24] ព័ត៌មានស្ដីពីការខ្វែងយោបល់គ្នានាពេលកន្លងទៅរវាងសហចៅក្រមស៊ើបអង្កេត[25] ការស្នើអ្នកស្រី អ៊ឹម ចែម ឱ្យចូលបង្ហាញខ្លួនលើកដំបូង[26] ដីកាបង្គាប់ឱ្យនាំខ្លួនអ្នកស្រី អ៊ឹម ចែម ដែលបានចេញរួចហើយ តែក្រោយមកត្រូវបានលុបចោលវិញ[27] ការចោទប្រកាន់អ្នកស្រី អ៊ឹម ចែម *ដោយកំបាំងមុខ*[28] ការផ្ទេរព័ត៌មាននានាពីសំណុំរឿង ០០៤/១[29] ការអនុវត្តកិច្ចសម្ភាសន៍របស់អ្នកស៊ើបអង្កេតមកពីការិយាល័យសហចៅក្រមស៊ើបអង្កេត[30] ការបិទកិច្ចស៊ើបសួរប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម[31] ព្រមទាំងការពិចារណានានាជុំវិញបញ្ហាកង្វះយុត្តាធិការរបស់ អ.វ.ត.ក លើរូបអ្នកស្រី អ៊ឹម ចែម[32] ។ នៅផ្នែកខាងក្រោម គឺជាការបង្ហាញឱ្យឃើញនូវហេតុផលជាក់លាក់ ដែលទាមទារឱ្យមានការចុះផ្សាយជាសាធារណៈនូវឯកសារទាក់ទងនឹងបញ្ហាទាំងនេះ ។

### ក. <u>ការចូលមើលឯកសារសំណុំរឿង</u>

១៥. ក្រុមការពារក្ដីស្វះស្វែងស្នើសុំឱ្យមានការចាត់ចំណាត់ប្រភេទឯកសារឡើងវិញ ចំពោះឯកសារមួយចំនួនដែលពាក់ព័ន្ធនឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីទទួលបានការអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿង ០០៤/១ នៅមុនការចោទប្រកាន់លើអ្នកស្រី អ៊ឹម ចែម[33] ។ ការចុះផ្សាយឯកសារ

---

24 ឧបសម្ព័ន្ធ A, ត្រង់លេខរៀង 1 – 3; ឧបសម្ព័ន្ធ B, ត្រង់លេខរៀង 1 – 2 ។

25 ឧបសម្ព័ន្ធ A, ត្រង់លេខរៀង 4 – 6; ឧបសម្ព័ន្ធ B, ត្រង់លេខរៀង 3 – 6 ។

26 ឧបសម្ព័ន្ធ A, ត្រង់លេខរៀង 7 – 16; ឧបសម្ព័ន្ធ B, ត្រង់លេខរៀង 7 – 13 ។

27 ឧបសម្ព័ន្ធ B, ត្រង់លេខរៀង 14 – 16 ។

28 ឧបសម្ព័ន្ធ A, ត្រង់លេខរៀង 17 – 21; ឧបសម្ព័ន្ធ B, ត្រង់លេខរៀង 17 – 19 ។

29 ឧបសម្ព័ន្ធ A, ត្រង់លេខរៀង 22 – 33; ឧបសម្ព័ន្ធ B, ត្រង់លេខរៀង 20 – 31 ។

30 ឧបសម្ព័ន្ធ A, ត្រង់លេខរៀង 34 – 39; ឧបសម្ព័ន្ធ B, ត្រង់លេខរៀង 32 – 37 ។

31 ឧបសម្ព័ន្ធ A, ត្រង់លេខរៀង 40 – 42; ឧបសម្ព័ន្ធ B, ត្រង់លេខរៀង 38 – 42 ។

32 ឧបសម្ព័ន្ធ A, ត្រង់លេខរៀង 43 – 47; ឧបសម្ព័ន្ធ B, ត្រង់លេខរៀង 43 – 48 ។

33 ឧបសម្ព័ន្ធ A, ត្រង់លេខរៀង 1 – 3; ឧបសម្ព័ន្ធ B, ត្រង់លេខរៀង 1 – 2 ។

ទាំងនេះ នឹងបម្រើឱ្យគោលដៅនៃការអប់រំដ៏សំខាន់មួយ ដោយផ្តល់ឱ្យសហគមន៍អ្នកច្បាប់កម្ពុជា នូវការពិចារណានានា ទាក់ទងនឹងសិទ្ធិរបស់ចុងចោទចំពោះការទទួលបាននូវឱកាសប្រកបដោយអត្ថន័យក្នុងការពិនិត្យមើល ការផ្តល់មតិយោបល់ទៅលើបញ្ហាអ្វីមួយ និងការជំទាស់លើភស្តុតាងទាំងឡាយ ដែលបានប្រមែប្រមូលសម្រាប់ដាក់តតាំងជាមួយភាគីចុងចោទនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ។ អំណះអំណាងរបស់ក្រុមការពារក្តីនៅក្នុងសំណុំរឿង ០០៤/១ លើកឡើងពីភាពពាក់ព័ន្ធនៃបញ្ហានីតិវិធីបែបនេះ ឆ្លើយតបទៅនឹងសិទ្ធិរបស់បុគ្គលម្នាក់ក្នុងការទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួនតាមផ្លូវច្បាប់ សិទ្ធិក្នុងការទទួលបានសមភាពរវាងគូភាគីក្នុងការតទល់រឿងក្តី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ទាំងមូល[34] ។ នៅក្នុងបរិបទដែលចុងចោទក្តី ឬអ្នកតំណាងផ្លូវច្បាប់របស់ពួកគេក្តី មិនត្រូវបានផ្តល់សិទ្ធិឱ្យពិនិត្យមើលឯកសារក្នុងសំណុំរឿងប្រឆាំងនឹងពួកគេ នៅមុនពេលការចាប់ផ្តើមធ្វើការជំនុំជម្រះ[35] ការពិចារណាទាំងនេះ គឺមានសារៈសំខាន់ណាស់ចំពោះដំណើរវិវឌ្ឍន៍ជាវិជ្ជមាននៃផ្នែកវិជ្ជាជីវៈតុលាការកម្ពុជា ។

## ខ. ការខ្វែងយោបល់គ្នាក្នុងតុលាការ

១៦. ក្រុមការពារក្តីស្វះស្វែងឱ្យមានការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ ចំពោះឯកសារទាំងឡាយដែលពាក់ព័ន្ធនឹងវិវាទទាក់ទងនឹងការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត កើតមាននៅ

[34] *សូមមើលជាឧទាហរណ៍,* សំណើរបស់អ្នកស្រី អ៊ឹម ចែម សុំដីកាសម្រេចអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿង ធ្វើនៅថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤, ឯកសារ **D201**; ទឡ្ហីករណ៍បន្ថែមលើសំណើរបស់អ្នកស្រី អ៊ឹម ចែម សុំដីកាសម្រេចអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿង ធ្វើនៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤, ឯកសារ **D201/2** ។

[35] *សូមមើលជាឧទាហរណ៍, របាយការណ៍របស់* សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) ស្តីពី៖ “សិទ្ធិមនុស្សឆ្នាំ ២០១២: ឆ្នាំស្ថិតក្នុងការពិនិត្យឡើងវិញ,” ចេញផ្សាយនៅខែ កុម្ភៈ ឆ្នាំ ២០១៣, ត្រង់ទំព័រ ១ [“ជារឿយៗដែលតុលាការមិនបានយកចិត្តទុកដាក់ទៅលើនីតិវិធីបញ្ញត្តិនានាដែលតម្រូវនៅក្នុងរឿងក្តីទាំងនេះទេ ជាហេតុធ្វើឱ្យក្រុមមេធាវីមកពីគម្រោងច្បាប់សិទ្ធិមនុស្ស (HRLP) មិនមានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី ។ ជួនកាល តុលាការបានបដិសេធមិនឱ្យមេធាវីជួបពិគ្រោះយោបល់ជាមួយកូនក្តីរបស់ពួកគេ ឬក៏អនុញ្ញាតឱ្យមេធាវីទាំងនោះ មើលសំណុំរឿងមុនពេលកាត់ក្តីឡើយ”] ។ របាយការណ៍អាចមើលបាននៅទីនេះ៖ http://www.licadho-cambodia.org/reports/files/176LICADHOReportHumanRightsReview2012English.pdf ។

ក្នុងសំណុំរឿង ០០៤/១[36] ។ ដោយគិតទៅដល់ការភ័ន្តច្រឡំរបស់សាធារណជន និងការអធិប្បាយស្តីពីការខ្វែងយោបល់គ្នារបស់ចៅក្រម[37] ការធ្វើបុព្វយោគលើសំណើទាំងឡាយរបស់ភាគីនានា នឹងផ្តល់នូវការបង្ហាញយ៉ាងត្រឹមត្រូវអំពីអានុភាពផ្លូវច្បាប់ និងចំណាត់ការផ្នែកនីតិវិធីដែលត្រូវបានអនុវត្តនៅក្នុងសំណុំរឿង ដើម្បីដោះស្រាយបញ្ហានៃការខ្វែងយោបល់គ្នារវាងចៅក្រម[38] ទាំងនេះជារួមវាជាគុណប្រយោជន៍ឆ្លើយតបទៅនឹងគោលដៅកេរដំណែលរបស់ អ.វ.ត.ក ។

គ. <u>ការចូលបង្ហាញខ្លួនលើកដំបូង</u>

១៧. ក្រុមការពារក្តីស្នើសុំឱ្យមានការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ ចំពោះឯកសារទាំងឡាយដែលពាក់ព័ន្ធនឹងការស្នើឱ្យអ្នកស្រី អ៊ឹម ចែម ចូលបង្ហាញខ្លួនលើកដំបូង[39] ។ ការចុះផ្សាយនូវឯកសារទាំងនេះ នឹងរួមចំណែកដល់គោលដៅអប់រំរបស់ អ.វ.ត.ក ដោយនាំយកព័ត៌មានចោទទាំងឡាយដាក់ចូលក្នុងមូលដ្ឋានសាធារណៈ ពោលគឺបញ្ហាទាក់ទងនឹងដំណើរការនីតិវិធីត្រឹមត្រូវសម្រាប់អនុវត្តតាមត្រង់ចំណុចប្រសព្វដ៏សំខាន់មួយនៃរឿងក្តីព្រហ្មទណ្ឌ ។ ឧទាហរណ៍ គឺរាប់ទាំងអំណះអំណាងមួយចំនួនដែលមានចេតនាផានាឱ្យបានថា ឯកសារតុលាការត្រូវបានផ្តល់ជូនចុង

---

[36] ឧបសម្ព័ន្ធ A, ត្រង់លេខរៀង 4 – 6; ឧបសម្ព័ន្ធ B, ត្រង់លេខរៀង 3 – 6 ។

[37] *សូមមើលជាឧទាហរណ៍, សេចក្តីប្រកាសព័ត៌មានរបស់* Open Society Foundations ក្រោមចំណងជើងថា៖ "ចៅក្រមថ្មីនឹងជួបឧបសគ្គធំចំពោះការតស៊ូនៅសាលាក្តីខ្មែរក្រហម," ចេញផ្សាយថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២, អាចមើលបាននៅទីនេះ៖ https://www.opensocietyfoundations.org/press-releases/new-judge-will-be-center-struggle-over-khmer-rouge-tribunal; *អត្ថបទរបស់* F. Donson ក្រោមចំណងជើងថា៖ "វិបត្តិនៅតែកើតមានបន្តទៀតនៅ អ.វ.ត.ក ខណៈដែលចៅក្រមស៊ើបអង្កេតលាលែងពីតំណែង" (ផ្សាយដោយ Centre for Criminal Justice and Human Rights ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១), អាចមើលបាននៅទីនេះ៖http://blogs.ucc.ie/wordpress/ccjhr/2011/10/11/yet-more-crisis-at-the-eccc-as-investigating-judge-resigns/ ។

[38] *សូមមើលជាឧទាហរណ៍,* សំណើរបស់អ្នកស្រី អ៊ឹម ចែម ស្នើសុំការបំភ្លឺលើបញ្ហាផ្លូវច្បាប់ដែលអាចនឹងកើតមាននៅ ពេលចេញដីកាដំណោះស្រាយទាក់ទងនឹងការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត, ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦, ឯកសារ **D293** ។

[39] ឧបសម្ព័ន្ធ A, ត្រង់លេខរៀង 7 – 16; ឧបសម្ព័ន្ធ B, ត្រង់លេខរៀង 7 – 13 ។

ចោទយ៉ាងត្រឹមត្រូវ[40] ហើយចុងចោទមានសិទ្ធិជំទាស់ទៅនឹងសុពលភាពនៃដំណើរប្រព្រឹត្តទៅនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ដោយអាចតវ៉ារកខុសត្រូវបាននៅពេលអាជ្ញាធរមិនបានអនុវត្តតាមនីតិវិធីច្បាប់ឱ្យបានត្រឹមត្រូវ[41] ។

ឃ. <u>ដីកាបង្គាប់ឱ្យនាំខ្លួន</u>

១៨. ក្រុមការពារក្តីស្នើសុំឱ្យមានការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ ចំពោះឯកសារទាំងឡាយដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចលុបចោលដីកាបង្គាប់ឱ្យនាំខ្លួនអ្នកស្រី អ៊ឹម ចែម[42] ។ ការនាំយកឯកសារទាំងនេះ ដាក់ចូលក្នុងមូលដ្ឋានសាធារណៈ នឹងជួយលើកកម្ពស់តម្លាភាពនៃសំណុំរឿង ០០៤/១ ។ ចំណុចសំខាន់នៅត្រង់ថា ខណៈដែលវត្តមាននៃដីកាបង្គាប់ឱ្យនាំខ្លួនអ្នកស្រី អ៊ឹម ចែម មាននៅក្នុងកំណត់ត្រាសាធារណៈ[43] មកទល់បច្ចុប្បន្ន សាធារណជនទូទៅនៅតែមិនដឹងថា ក្រោយមកដីកានេះ ត្រូវបានលុបចោលវិញនោះឡើយ[44] ។ អាស្រ័យហេតុនេះ ការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ នឹងផ្តល់ឱ្យសាធារណជននូវការយល់ដឹងបានពេញលេញ និងត្រឹមត្រូវជាងមុនអំពីបញ្ហានេះ ដែលនៅទីបំផុតទៅ វាជះឥទ្ធិពលលើការយល់ឃើញរបស់សាធារណជនចំពោះអ្នកស្រី អ៊ឹម ចែម ។

ង. <u>ការចោទប្រកាន់*ដោយកំបាំងមុខ*</u>

១៩. ក្រុមការពារក្តីស្នើសុំឱ្យមានការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ ចំពោះឯកសារទាំងឡាយ

---

[40] *សូមមើលជាឧទាហរណ៍,* លិខិតទាក់ទងនឹងបញ្ហា “ទម្រង់បែបបទនៃការប្រគល់ដីកាកោះជូនអ្នកស្រី អ៊ឹម ចែម,” ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៤, ឯកសារ **A122/5** ។

[41] *សូមមើលជាឧទាហរណ៍, សំណើសុំបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម ស្នើសុំឱ្យបញ្ជូនសំណើសុំមោឃភាពដីកាកោះហៅអ្នកស្រី និងសហមេធាវីការពារក្តីគាត់ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤ ទៅអង្គបុរេជំនុំជម្រះ,”* ធ្វើនៅថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១៤, ឯកសារ **D207** ត្រង់កថាខណ្ឌ ១៩-២៧ ។

[42] ឧបសម្ព័ន្ធ B, ត្រង់លេខរៀង 14 – 16 ។

[43] *សូមមើល, រឿងក្តី មាស មុត,* សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩/អវកត/កសចស, សំបុត្ររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ជូនឯកឧត្តម ឯម សំអាន, លិខិតចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥, ឯកសារ **D127** ។

[44] *សូមមើល,* ដីកាសម្រេចលុបចោលដីកាបង្គាប់ឱ្យនាំខ្លួន អ៊ឹម ចែម ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦, ឯកសារ **C1/1** ។

ដែលទាក់ទងនឹងការចោទប្រកាន់អ្នកស្រី អ៊ឹម ចែម *ដោយកំបាំងមុខ*[45] ។ សម្ភារៈតឹកតាងបែបនេះ នឹងក្លាយជាប្រភពអប់រំដ៏មានតម្លៃសម្រាប់អ្នកមានវិជ្ជាជីវៈច្បាប់នៅកម្ពុជា នៅក្នុងការវាយតម្លៃពីភាពស្របច្បាប់នៃនីតិវិធីនេះ ។ ចំណុចជាក់លាក់ គឺវិវាទជុំវិញបណ្តឹងឧទ្ធរណ៍របស់ក្រុមការពារក្តី ប្រឆាំងនឹងការចោទប្រកាន់អ្នកស្រី អ៊ឹម ចែម *ដោយកំបាំងមុខ*[46] មានអំណះអំណាងពិស្តារ និងគ្របដណ្តប់ទៅដោយការពិចារណានានា ជុំវិញភាពស្របច្បាប់នៃដំណើរប្រព្រឹត្តទៅលើវិធានការនេះ នៅក្រោមច្បាប់កម្ពុជា ។

### ច. <u>ការដាក់បញ្ចូលព័ត៌មានទៅក្នុងសំណុំរឿង</u>

២០. ក្រុមការពារក្តីស្វះស្វែងឱ្យមានការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ នូវឯកសារទាំងឡាយដែលពាក់ព័ន្ធនឹងសំណើសុំដាក់ឯកសារជាក់លាក់មួយចំនួនទៅក្នុងសំណុំរឿង[47] ។ ការចុះផ្សាយឯកសារទាំងនេះ នឹងបម្រើឱ្យគោលដៅនៃការអប់រំមួយ ដែលអាចនឹងត្រូវបានយកទៅប្រើប្រាស់សម្រាប់ការអនុវត្តច្បាប់នៅប្រទេសកម្ពុជា ដោយផ្តល់នូវការបង្ហាញរបស់ភាគីកំពុងស្វែងរកប្រយោជន៍ពីមធ្យោបាយនីតិវិធីនានា ដើម្បីធានានូវភាពយុត្តិធម៌ផ្នែកនីតិវិធី និងភស្តុតាង ។ មធ្យោបាយនីតិវិធីបែបនេះ រាប់បញ្ចូលទាំងសំណើសុំបំពេញកិច្ចស៊ើបសួរ[48] សំណើទាក់ទងនឹងការស្នើសុំខ្សែអាត់សំឡេង និងរូបភាពនៃកំណត់ហេតុស្តាប់ចម្លើយសាក្សី[49] និងសំណើសុំឱ្យមានការដាក់បង្ហាញ

---

[45] ឧបសម្ព័ន្ធ A, ត្រង់លេខរៀង 17 – 21; ឧបសម្ព័ន្ធ B, ត្រង់លេខរៀង 17 – 19 ។

[46] *សូមមើលជាឧទាហរណ៍,* បណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អ៊ឹម ចែម ប្រឆាំងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ធ្វើនៅថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥, ឯកសារ **D239/1/2**។

[47] ឧបសម្ព័ន្ធ A, ត្រង់លេខរៀង 22 – 33; ឧបសម្ព័ន្ធ B, ត្រង់លេខរៀង 20 – 31 ។

[48] *សូមមើលជាឧទាហរណ៍,* សំណើលើកទី១ របស់អ្នកស្រី អ៊ឹម ចែម សុំបំពេញកិច្ចស៊ើបសួរ ធ្វើថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥, ឯកសារ **D279** ។

[49] *សូមមើលជាឧទាហរណ៍,* សំណើរបស់អ្នកស្រី អ៊ឹម ចែម ស្នើសុំខ្សែអាត់សំឡេង និងរូបភាពនៃកំណត់ហេតុស្តាប់ចម្លើយដែលមាននៅក្នុងសំណុំរឿង០០៤ ធ្វើថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥, ឯកសារ **D247** ។

សម្ភារៈតឹកតាងនានាដែលមានក្នុងនីតិវិធីច្បាប់ដាច់ដោយឡែកពីគ្នា[50] ។

### ឆ. ការអនុវត្តកិច្ចស៊ើបសួរ

២១. ក្រុមការពារក្ដីស្នះស្វែងឱ្យមានការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ នូវឯកសារមួយចំនួនដែលពាក់ព័ន្ធនឹងការអនុវត្តកិច្ចសម្ភាសន៍របស់បុគ្គលិកមកពីការិយាល័យសហចៅក្រមស៊ើបអង្កេត[51] ។ នៅក្នុងសារណារបស់ក្រុមការពារក្ដី ការចុះផ្សាយនូវឯកសារទាំងនេះ នឹងក្លាយជាឧបករណ៍អប់រំដ៏មានតម្លៃដល់បុគ្គលិកផ្នែកស៊ើបអង្កេតក្នុងប្រទេស ដោយការចង្អុលបង្ហាញពីបទដ្ឋាននានាដែលតម្រូវឱ្យមានចំពោះការអនុវត្តកិច្ចស៊ើបសួរត្រឹមត្រូវតាមច្បាប់ និងបង្ហាញដល់មេធាវីថាតើវិធីបង្ហាញភស្តុតាងមានវិការៈដែលអាចតវ៉ាបាន ទំនងជាតតាំងបានយ៉ាងសមស្រប ។ ការដាក់ឯកសាររបស់ក្រុមការពារក្ដីលើបញ្ហានេះ ពាក់ព័ន្ធទាំងការប្រតិបត្តិកិច្ចស៊ើបអង្កេតផង[52] និងផលវិបាកកើតចេញពីភស្តុតាងដែលត្រូវបានប្រមូលដោយមិនត្រឹមត្រូវផង[53] ។

### ជ. ការបិទកិច្ចស៊ើបសួរ

២២. ក្រុមការពារក្ដីស្នះស្វែងឱ្យមានការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ នូវឯកសារមួយចំនួនដែលទាក់ទងនឹងការបិទកិច្ចស៊ើបសួរតាមផ្លូវតុលាការប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម និងការបំបែកអ្នកស្រីចេញពីដំណើរការនីតិវិធីនៃសំណុំរឿង 004/1[54] ។ ការអនុញ្ញាតឱ្យចុះផ្សាយឯកសារទាំង

---

[50] *សូមមើលជាឧទាហរណ៍,* សំណើរបស់អ្នកស្រី អ៊ឹម ចែម ស្នើឱ្យដាក់បង្ហាញរាល់ប្រតិចារឹកនៃសំណុំរឿង002 ដែលមិនមែនជាសំណៅកោសលុប ព្រមទាំងឯកសារមួយចំនួនទៀតដែលពាក់ព័ន្ធនឹងអ្នកស្រី ធ្វើថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៥, ឯកសារ **D283** ។

[51] ឧបសម្ព័ន្ធ A, ត្រង់លេខរៀង 34 – 39; ឧបសម្ព័ន្ធ B, ត្រង់លេខរៀង 32 – 37 ។

[52] *សូមមើលជាឧទាហរណ៍,* ញត្តិរបស់អ្នកស្រី អ៊ឹម ចែម ស្នើសុំសហចៅក្រមស៊ើបអង្កេតឲ្យបន្តធ្វើការថតយកសំឡេង ឬរូបភាព នូវរាល់ការស្ដាប់យកចម្លើយទាំងអស់ ធ្វើថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥, ឯកសារ **D252** ។

[53] *សូមមើលជាឧទាហរណ៍,* សំណើរបស់អ្នកស្រី អ៊ឹម ចែម ស្នើឱ្យប្ដឹងទៅអង្គបុរេជំនុំជម្រះសុំឱ្យទទួលពិនិត្យ និងចាត់ការលើសំណើសុំធ្វើមោឃភាពប្រតិចារិក និងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយសាក្សីមួយចំនួន ធ្វើថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៦, ឯកសារ **D298** ។

[54] ឧបសម្ព័ន្ធ A, ត្រង់លេខរៀង 40 – 42; ឧបសម្ព័ន្ធ B, ត្រង់លេខរៀង 38 – 42 ។

នេះទៅក្នុងមូលដ្ឋានសាធារណៈ នឹងបម្រើឱ្យគោលដៅទាំងពីរ គឺការអប់រំ និងកេរដំណែល ។ ទាក់ទងនឹងការអប់រំ ការចុះផ្សាយនូវសំណើនានាឆ្លើយតបទៅនឹងការបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងអ្នកស្រី អ៊ឹម ចែម នឹងផ្តល់ឱ្យសហគមន៍អ្នកច្បាប់កម្ពុជានូវការយល់ដឹងអំពីភាពសំខាន់នៃសិទ្ធិការពារក្តី ពិសេសបំផុត គឺសិទ្ធិធ្វើការឆ្លើយតបនៅក្នុងដំណាក់កាលមុនការជំនុំជម្រះក្តី[55] ។ ចំណែកឯទស្សនវិស័យនៃកេរដំណែលរបស់ អ.វ.ត.ក ការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ តួយ៉ាងចំពោះឯកសារទាំងឡាយណាដែលពាក់ព័ន្ធនឹងចេតនារបស់សហចៅក្រមស៊ើបអង្កេត ក្នុងការច្រានចោលបទចោទប្រកាន់ប្រឆាំងអ្នកស្រី អ៊ឹម ចែម[56] នឹងជួយដល់សាធារណជនអាចស្វែងយល់ពីការប្រព្រឹត្តទៅនៃដំណើរការនីតិវិធីដ៏ពេញលេញ ធ្វើឱ្យឈានដល់ការសន្និដ្ឋានដែលបានសម្រេចនៅក្នុងដីកាដំណោះស្រាយរបស់ពួកគេ និងកាត់បន្ថយការព្រួយបារម្ភចំពោះបញ្ហាចោទដែលថាសេចក្តីសម្រេចនេះ ធ្វើឡើងដោយមិនមានការពិចារណាតាមផ្លូវច្បាប់ឱ្យបានគ្រប់គ្រាន់ ឬខកខានមិនបានធ្វើតាមនីតិវិធីត្រឹមត្រូវជាដើម[57] ។

ឈ. <u>ការពិចារណាលើបញ្ហាយុត្តាធិការបុគ្គល</u>

២៣. ក្រុមការពារក្តីស្នះស្វែងឱ្យមានការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ នូវឯកសារដែលពាក់ព័ន្ធនឹង

---

55 *សូមមើលជាឧទាហរណ៍,* សារណារបស់អ្នកស្រី អ៊ឹម ចែម លើការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតចំពោះការមាន បំណងបោះបង់នូវបទចោទប្រកាន់ និងបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងអ្នកស្រី ធ្វើនៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦, ឯកសារ **D286/2**; ចម្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងការបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងអ្នកស្រី ធ្វើនៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦, ឯកសារ **D286/3/1** ។

56 សេចក្តីជូនដំណឹងអំពីគោលបំណងលើកលែងការចោទប្រកាន់ប្រឆាំង អ៊ឹម ចែម និងបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **D286** ។

57 *សូមមើលជាឧទាហរណ៍, អត្ថបទរបស់* E. Handley ក្រោមចំណងជើងថា "កង្វះសំអាងហេតុក្នុងរឿងក្តី អ៊ឹម ចែម" (កាសែតភ្នំពេញប៉ុស្តិ៍ ចុះផ្សាយនៅថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៧), អាចមើលបាននៅទីនេះ៖ https://www.phnompenhpost.com/national/im-chaem-filing-short-reasoning; *អត្ថបទរបស់* E. Handley ក្រោមចំណងជើងថា "សាលាក្តីកែសម្រួលសេចក្តីសម្រេចលើរឿងក្តី អ៊ឹម ចែម បង្កឱ្យមានកំហឹង" (កាសែតភ្នំពេញប៉ុស្តិ៍ ផ្សាយនៅថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៧), មើលនៅទីនេះ៖ https://www.phnompenhpost.com/national/tribunals-edited-decision-im-chaem-draws-ire ។

សំណួរចោទស្តីពីបញ្ហាយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក លើរូបអ្នកស្រី អ៊ឹម ចែម[58]។ ការចុះផ្សាយឯកសារទាំងនេះ ក៏នឹងអាចរួមផ្តល់វិភាគទានដល់តម្លៃអប់រំ និងកេរដំណែលរបស់តុលាការដូចគ្នា។ ឧទាហរណ៍ ឯកសារកំពុងចោទគឺពោរពេញទៅដោយព័ត៌មានដ៏មានសារៈប្រយោជន៍ ដោយសារព័ត៌មានបែបនោះ គឺជាការពន្យល់ពីសំណួរចោទលើបញ្ហាផ្លូវច្បាប់ពាក់ព័ន្ធនឹងដំណាក់កាលមុនការជំនុំជម្រះនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ រួមមានដូចជានីតិវិធី និងបទដ្ឋានស្តីពីការបង្ហាញភស្តុតាងសម្រាប់ធ្វើការវាយតម្លៃទៅលើសំណួរចោទមួយចំនួន ចំពោះបញ្ហាយុត្តាធិការ[59] ។ ម៉្យាងវិញទៀត ការនាំយកមាតិការឿងនៃវិវាទលើប្រធានបទនេះដាក់ក្នុងមូលដ្ឋានសាធារណៈ នឹងនាំឱ្យកេរដំណែលរបស់ អ.វ.ត.ក ត្រូវបានលើកកម្ពស់ ពីព្រោះសាធារណជននឹងមានឱកាសពិនិត្យពិច័យបានហ្មត់ចត់លើអំណះអំណាងនានា ជុំវិញប្រតិបត្តិការនៃលក្ខណៈវិនិច្ឆ័យចំពោះយុត្តាធិការបុគ្គលដ៏ប្លែកពីគេរបស់ អ.វ.ត.ក និងការចូលរួមចំណែករបស់ខ្លួនចំពោះផ្នែកសម្រេចសេចក្តីជាចុងក្រោយលើសំណុំរឿង ០០៤/១ នៅក្នុងបរិបទពេញលេញ និងត្រឹមត្រូវ[60] ។

### ញ. <u>ការកែតម្រូវលើភាពមិនប្រក្រតីខ្លះនៅក្នុងចំណាត់ថ្នាក់ឯកសារនៃសំណុំរឿង ០០៤/១</u>

២៤. បន្ថែមលើការពិចារណាខាងលើ ដោយផ្តោតចំពោះករណីជាក់លាក់ ក្រុមការពារក្តីសូមស្នើអង្គបុរេជំនុំជម្រះដោយគោរព មេត្តាធ្វើចំណាត់ប្រភេទឯកសារឡើងវិញជាផ្លូវការនូវព័ត៌មានដែលគួរតែត្រូវបានចុះផ្សាយជាសាធារណៈ។ ជាពិសេស ក្រុមការពារក្តីសូមស្នើឱ្យធ្វើចំណាត់ប្រភេទឯកសារ

---

[58] ឧបសម្ព័ន្ធ A, ត្រង់លេខរៀងឧបសម្ព័ន្ធ 43 – 47; ឧបសម្ព័ន្ធ B, ត្រង់លេខរៀង 43 – 48 ។

[59] *សូមមើលជាឧទាហរណ៍,* សេចក្តីសង្កេតរបស់អ្នកស្រី អ៊ឹម ចែម ស្តីពីបញ្ហាថាតើអ្នកស្រីគួរត្រូវបានចាត់ទុកជា "មេដឹកនាំជាន់ខ្ពស់" ឬ បុគ្គលម្នាក់ស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ធ្វើនៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៥, ឯកសារ **D251/4** ត្រង់កថាខណ្ឌ ៥ ដល់ ១១ ។

[60] *សូមមើលជាឧទាហរណ៍,* សេចក្តីសង្កេតរបស់អ្នកស្រី អ៊ឹម ចែម ស្តីពីបញ្ហាថាតើអ្នកស្រីគួរត្រូវបានចាត់ទុកជា "មេដឹកនាំជាន់ខ្ពស់" ឬ បុគ្គលម្នាក់ស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ធ្វើនៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៥, ឯកសារ **D251/4** ត្រង់កថាខណ្ឌ ១២ ដល់ ៦០; ការឆ្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងសារណារបស់សហព្រះរាជអាជ្ញាអន្តរជាតិលើបញ្ហាថាតើអ្នកស្រីគួរត្រូវបានចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់" ឬបុគ្គលម្នាក់ក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ២០១៥, ឯកសារលេខ **D251/5/3** ត្រង់កថាខណ្ឌ ៧ ដល់ ២១ ។

ឡើងវិញនូវឯកសារ៖

- ដីការបស់អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon លើញត្តិរបស់ជនសង្ស័យ ស្នើសុំឱ្យមានការស្រាយបំភ្លឺទាក់ទិននឹងការខ្វែងយោល់ គ្នារវាងសហចៅក្រមស៊ើបអង្កេត[61] ។ ក្រុមការពារក្តីកត់សម្គាល់ឃើញថា ឯកសារនេះត្រូវបានចុះក្នុងបញ្ជីឯកសារសំណុំរឿងជាទម្រង់ឯកសារកោសលុបសាធារណៈ តែទោះជាយ៉ាងណាក្តី សំណៅឯកសារនេះ ត្រូវបានដាក់ជាប្រភេទឯកសារសម្ងាត់[62] ។
- សំបុត្ររបស់អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon ជូនឯកឧត្តម ឯម សំអាន[63]។ ក្រុមការពារក្តីកត់សម្គាល់ឃើញថា ឯកសារចម្លងដូចគ្នានៃឯកសារនេះ ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង ០០៣ និងក៏ត្រូវបានចុះផ្សាយនៅលើគេហទំព័ររបស់តុលាការដែរ[64] ។

ក្រុមការពារក្តីទទួលស្គាល់ថា ឯកសារដែលត្រូវស្នើសុំ គឺគ្របដណ្តប់នូវឯកសារពាក់ព័ន្ធនឹងវិសាលភាពដ៏សំខាន់នៃសំណុំរឿងទាំងមូល ។ ទោះបីសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញមានវិសាលភាពទូលំទូលាយក្តី ក៏សំណើនេះ ជាក់ស្តែងគឺធ្វើឡើងដោយផ្អែកតាមសេចក្តីសម្រេចថ្មីៗរបស់អង្គបុរេជំនុំជម្រះ[65] ដោយស្របទៅនឹងវិធីសាស្ត្រនៃអង្គបុរេជំនុំជម្រះលើការធ្វើចំណាត់

---

[61] ដីកាសម្រេចលើញត្តិរបស់ជនសង្ស័យ ស្នើសុំឱ្យមានការស្រាយបំភ្លឺទាក់ទិននឹងការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤, ឯកសារ **D204/2** ។

[62] *សូមមើល,* ដីកាសម្រេចលើញត្តិរបស់ជនសង្ស័យ ស្នើសុំឱ្យមានការស្រាយបំភ្លឺទាក់ទិននឹងការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤, ឯកសារ **D208/1.1** ។

[63] សំបុត្ររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ជូនឯកឧត្តម ឯម សំអាន, លិខិតចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥, ឯកសារ **D238** ។

[64] *សូមមើល, រឿងក្តី មាស មុត,* សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩/អវកត/កសចស, សំបុត្ររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ជូនឯកឧត្តម ឯម សំអាន, លិខិតចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥, ឯកសារ **D127** ។ អាចមើលបាននៅទីនេះ៖ https://www.eccc.gov.kh/en/document/court/icijs-letter-he-mr-em-sam ។

[65] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើការកោសលុប ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨, ឯកសារ **D309/2/1/7**; សេចក្តីសម្រេចលើសំណើរបស់ អ៊ឹម ចែម សុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតប

ប្រភេទឯកសារនានា ក្នុងបំណងដើម្បី "ចូលរួមចំណែកលើគោលការណ៍តម្លាភាពនៃយុត្តិធម៌កេរដំណែល អ.វ.ត.ក និងគោលដៅសំខាន់គឺការអប់រំ និងការស្វែងរកយុត្តិធម៌"[66] ។ ក្រុមការពារក្តីយល់ឃើញថា អាជ្ញាបែបនេះ គួរតែជាវិធីគាំទ្រដ៏ល្អបំផុតក្នុងសំណុំរឿង ០០៤/១ តាមរយៈការធ្វើចំណាត់ប្រភេទឯកសារដែលបានស្នើសុំ ជាប្រភេទឯកសារសាធារណៈ ។

**ខ. ការធ្វើការចំណាត់ប្រភេទឯកសារឡើងវិញ លើឯកសារដែលបានស្នើសុំ នឹងមិនប៉ះពាល់ដល់សម្ភារៈតឹកតាងសម្ងាត់របស់ អ.វ.ត.ក ឡើយ**

២៥. ការធ្វើចំណាត់ប្រភេទឯកសារ ត្រូវតែកំណត់តាមរយៈការវាយតម្លៃលើការពិចារណាខុសៗគ្នា ដើម្បីការធានាការពារនូវព័ត៌មានរសើប រួមទាំងនីតិវិធីដែលកំពុងបន្តប្រព្រឹត្តទៅនៅ អ.វ.ត.ក ហានិភ័យនៃផលប៉ះពាល់ចំពោះបុគ្គលដែលត្រូវបានចោទប្រកាន់ ឬស្ថិតក្រោមការស៊ើបអង្កេតស្រាប់ និងបញ្ហាផ្សេងៗទៀតដែលអាស្រ័យផលលើភាពសម្ងាត់[67] ។

---

របស់គាត់ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨, ឯកសារ **D304/6/4** ។

[66] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើការកោសលុប ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨, ឯកសារ **D309/2/1/7** ត្រង់កថាខណ្ឌ ៣៩ ។

[67] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច" សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អជតក*, សេចក្តីសម្រេចលើគោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២, ឯកសារ **F30/2**, ត្រង់កថាខណ្ឌ ៦ ["ដោយហេតុថា កិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០១ បានបញ្ចប់រួចហើយ ការដកចំណាត់ថ្នាក់ឯកសារដែលពាក់ព័ន្ធកិច្ចស៊ើបសួរ លែងមានហានិភ័យជាទូទៅនៃការប៉ះពាល់លើសិទ្ធិរបស់ជនជាប់ចោទ ឬសុចរិតភាពនៃកិច្ចស៊ើបសួរ ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ជាគោលការណ៍ ឯកសារប្រភេទនេះទាំងអស់ត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញថាជាឯកសារសាធារណៈ ដូច្នេះត្រូវអនុញ្ញាតឱ្យសាធារណជនទូទៅ មានលទ្ធភាពពេញលេញនៅក្នុងការពិនិត្យមើលឯកសារ និងពង្រីកឱ្យមានតម្លាភាពដល់កម្រិតអតិបរិមា ។ នៅក្នុងពេលជាមួយគ្នានេះ ដោយពិចារណាឃើញថា កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក នៅកំពុងបន្តដំណើរការនៅឡើយ ហើយបន្ទាប់ពីបញ្ចប់កិច្ចដំណើរការនីតិវិធីនេះ ការសម្ងាត់ចំពោះសំអាងមួយចំនួន អាចនៅតែរក្សាទុកការពារមួយចំនួនចាំបាច់តម្រូវឱ្យមានដូចដែលមានកំណត់នៅក្នុងគោលការណ៍ណែនាំខាងក្រោម"] ។

២៦. ទាក់ទងនឹងការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនូវឯកសារ នៅក្នុងសំណុំរឿង ០០៤/១ អង្គបុរេជំនុំជម្រះបានយកវិធីសាស្ត្រដូចខាងក្រោមដើម្បីអនុវត្តការកោសលុប៖

- អនុវត្តការកោសលុបលើឈ្មោះបុគ្គលដែលស្ថិតនៅក្រោម ឬបុគ្គលដែលជាប់ពាក់ព័ន្ធនឹងវិធានការការពារ[68] ។ អត្តសញ្ញាណនៃបុគ្គលប្រភេទនេះនៅក្នុងសំណុំរឿង ០០៤/១ ដែលត្រូវបានផ្តល់ដោយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ[69] និងបានពីសហចៅក្រមស៊ើបអង្កេត[70] ។
- រក្សាទុកដោយមិនធ្វើការកោសលុបលើឈ្មោះអ្នកស្រី អ៊ឹម ចែម និងការយោងដល់ ឬការដកស្រង់ចេញពីសេចក្តីថ្លែងការណ៍របស់អ្នកស្រី[71] ។
- រក្សាទុកដោយមិនធ្វើការកោសលុប លើឈ្មោះរបស់កម្មាភិបាលខ្មែរក្រហមដែលបានស្លាប់

---

[68] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើការកោសលុប ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨, ឯកសារ **D309/2/1/7** ត្រង់កថាខណ្ឌ ៣៨; សេចក្តីសម្រេចលើសំណើរបស់ អ៊ឹម ចែម សុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតបរបស់គាត់ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨, ឯកសារ **D304/6/4** ត្រង់កថាខណ្ឌ ២៣ និង ៣១ ។

[69] អង្គភាពគាំពារសាក្សី និងអ្នកជំនាញ (WESU)៖ ការវាយតម្លៃពីហានិភ័យ ធ្វើនៅថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៨, ឯកសារ **D309/2/1/5/1**; របាយការណ៍ពីប្រព័ន្ធគ្រប់គ្រងសំណុំរឿង (Case Map) អ៊ឹម ចែម ដែលទាក់ទងនឹងជនរងគ្រោះ និងបុគ្គលទាំងឡាយណាដែលបានស្នើសុំវិធានការការពារ – ១៥.មករា. ២០១៦, ធ្វើនៅថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៨, ឯកសារ **D309/2/1/5/1.2** ។

[70] អនុស្សរណៈដែលមានចំណងជើងថា " ចម្លើយតបទៅនឹងសេចក្តីបង្គាប់របស់ អ.ប.ជ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៨ – D309/2/1/6" ធ្វើនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៨, ឯកសារ **D309/2/1/6/1**; ឧបសម្ព័ន្ធ I៖ វិធានការការពារក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) នៃសំណុំរឿង ០០៤/០១ នៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៨, ឯកសារ **D309/2/1/6/1.1**; ឧបសម្ព័ន្ធ II៖ វិធានការការពារនៃសំណុំរឿង ០០៤/០១ នៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៨, ឯកសារ **D309/2/1/6/1.2** ។

[71] សេចក្តីសម្រេចលើសំណើរបស់ អ៊ឹម ចែម សុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតបរបស់គាត់ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨, ឯកសារ **D304/6/4** ត្រង់កថាខណ្ឌ ២០ ដល់ ២១ ។

ទៅហើយ[72] ។

២៧. ដោយផ្អែកលើវិធីសាស្ត្រខាងលើ ក្រុមការពារក្តីបានពិនិត្យសាឡើងវិញនូវឯកសារដែលបានដាក់ទាំងអស់ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ A និងឈានដល់ការសន្និដ្ឋានបានថា គ្មានការកោសលុបណាត្រូវបានអនុវត្តនៅឡើយទេ ។ ហេតុដូច្នេះ ក្រុមការពារក្តីសូមស្នើឱ្យដាក់ចំណាត់ឯកសារឡើងវិញជាប្រភេទឯកសារ “សាធារណៈ” ចំពោះសំណៅឯកសារមួយចំនួនដែលបង្ហាញនៅក្នុងឧបសម្ព័ន្ធ A បច្ចុប្បន្នកំពុងមានស្រាប់នៅក្នុងសំណុំរឿង ០០៤/១ ។

២៨. ទោះបីវិធីសាស្ត្រខាងលើទាក់ទងនឹងការកោសលុបក៏ដោយ ក៏ក្រុមការពារក្តីយល់ថា វាជាការសមស្របក្នុងការស្នើសុំអង្គបុរេជំនុំជម្រះមេត្តាចាប់អារម្មណ៍ទៅលើការយោង ឬដកស្រង់ពីអត្តិភាពនៃកិច្ចស៊ើបអង្កេតលើកំហុសវិជ្ជាជីវៈដោយបុគ្គលិក អ.វ.ត.ក ។ បញ្ហានេះ ត្រូវបានលើកឡើងរួចមកហើយនៅក្នុងសំណើចំនួនបីរបស់ក្រុមការពារក្តី[73] ។ ក្រុមការពារក្តីសូមស្វាគមន៍ចំពោះការបង្ហាញរឿងរ៉ាវទាំងនេះជាសាធារណៈ ហើយមិនស្នើសុំឱ្យធ្វើកោសលុបព័ត៌មាននេះទេ នាពេលបច្ចុប្បន្ន ។ ទោះបីជាយ៉ាងណា ក្រុមការពារក្តីនឹងធ្វើតាមសេចក្តីណែនាំផ្ទុយពីនេះ តាមការសម្រេចរបស់អង្គជំនុំជម្រះ ។

២៩. លើសពីនេះ ក្រុមការពារក្តីសំណូមពរថា ការកោសលុបលើឯកសារនានាដែលបានដាក់ដោយអង្គចៅក្រម គឺជាភារកិច្ចដែលនឹងត្រូវអនុវត្តដោយអង្គជំនុំជម្រះសាមី ឬដោយអង្គបុរេជំនុំ

---

72 សេចក្តីសម្រេចលើសំណើរបស់ អ៊ឹម ចែម សុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតបរបស់គាត់ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨, ឯកសារ **D304/6/4** ត្រង់កថាខណ្ឌ ២២ ។

73 សំណើរបស់អ្នកស្រី អ៊ឹម ចែម ស្នើឱ្យប្តឹងទៅអង្គបុរេជំនុំជម្រះសុំឱ្យទទួលពិនិត្យ និងចាត់ការ លើសំណើសុំធ្វើមោឃភាពប្រតិចារិក និងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សីមួយចំនួន ធ្វើថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៦, ឯកសារ **D298** ត្រង់កថាខណ្ឌ ៣០ ដល់ ៣១, កថាខណ្ឌ ៤២, ត្រង់យោងជើងទំព័រលេខ ៧៥; ការឆ្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីពាក្យស្នើសុំរបស់អ្នកស្រីឱ្យមោឃភាពលើកំណត់ហេតុស្តាប់ចម្លើយសាក្សីមួយចំនួន ធ្វើថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦, ឯកសារ **D298/2/1/2** ត្រង់កថាខណ្ឌ ៩; ញត្តិរបស់អ្នកស្រី អ៊ឹម ចែម ស្នើសុំសហចៅក្រមស៊ើបអង្កេតឲ្យបន្តធ្វើការថតយកសំឡេង ឬ រូបភាពនូវរាល់ការស្តាប់យកចម្លើយទាំងអស់ ធ្វើថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥, ឯកសារ **D252** ត្រង់កថាខណ្ឌ ៣០ ។

ជម្រះខ្លួនឯង ដែលប្រការនេះ គឺវាស្របគ្នាជាមួយនឹងវិធីសាស្ត្រអង្គបុរេជំនុំជម្រះបានអនុវត្តកាលពីកន្លងមក[74] ។

៣០. ចុងក្រោយបង្អស់ ក្នុងខណៈដែលឯកសារត្រូវស្នើសុំ គឺរាប់បញ្ចូលតែឯកសារទាំងឡាយណាដែលដាក់ដោយក្រុមការពារក្ដី ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត និងដោយអង្គបុរេជំនុំជម្រះក៏ដោយចុះ ក្រុមការពារក្ដីទទួលស្គាល់ថា ភាគីទាំងអស់ក្នុងសំណុំរឿង ០០៤/១ សុទ្ធតែទទួលបាននូវអត្ថប្រយោជន៍ការមានតម្លាភាពនៃកិច្ចដំណើរការនីតិវិធី ។ ទោះជាយ៉ាងណា ចំណុចនេះយើងខ្ញុំជូនជាសំណូមពរថា វាជាការសមស្របបំផុតសម្រាប់ភាគីសាមី ធ្វើការស្នើសុំរៀងៗខ្លួនថាតើឯកសារណាខ្លះ ដែលពួកគេគប្បីត្រូវស្នើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញជាឯកសារសាធារណៈ ។ ក្រុមការពារក្ដីសូមរក្សាសិទ្ធិរបស់ខ្លួនក្នុងការឆ្លើយតបទៅនឹងសំណើដូច្នេះ តាមពេលវេលាសមគួរ ។ ជម្រើសផ្សេងពីនេះ ដើម្បីជាប្រយោជន៍នៃតម្លាភាពនីតិវិធី និងដើម្បីបង្កើតនូវកំណត់ហេតុសាធារណៈដ៏ពេញលេញមួយ ក្រុមការពារក្ដីស្វាគមន៍ជានិច្ចនូវរាល់សេចក្ដីបង្គាប់របស់អង្គបុរេជំនុំជម្រះទៅកាន់ភាគីផ្សេងៗទៀតនៃសំណុំរឿង ០០៤/១ ដែលជាការតម្រូវឱ្យធ្វើចំណាត់ប្រភេទឯកសារឡើងវិញ លើរាល់សំណើនានារបស់ភាគីទាំងនោះ ។

## I. សំណើ

ចំពោះហេតុផលដែលបានលើកឡើងខាងលើ ក្រុមការពារក្ដីសូមស្នើអង្គបុរេជំនុំជម្រះដោយគោរព មេត្តា i) បង្គាប់ដល់ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះឱ្យដាក់ឯកសារដែលបានស្នើសុំក្នុងឧបសម្ព័ន្ធ A និង ឧបសម្ព័ន្ធ B នៃសំណើនេះ ជាប្រភេទឯកសារសាធារណៈ ឬជាទម្រង់

---

[74] សេចក្ដីសម្រេចលើសំណើរបស់ អ៊ឹម ចែម សុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតបរបស់គាត់ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨, ឯកសារ **D304/6/4** នៅត្រង់ទំព័រ ១២ ដល់ ១៣; សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើការកោសលុប ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨, ឯកសារ **D309/2/1/7** ត្រង់ទំព័រ ១៣ ។

កោសលុបសាធារណៈ និង ii) ស្នើសុំឱ្យដាក់សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនេះ ជាប្រភេទឯកសារសាធារណៈ ។

សូមមេត្តាទទួលយកសារណានេះដោយគោរព ៕

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជាថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៨

សហមេធាវីការពារក្តីអ្នកស្រី អ៊ឹម ចែម

[ហត្ថលេខា] [ហត្ថលេខា]

ប៊ិត ស៊ាងលឹម Wayne JORDASH, QC